

រូបថត៖ អង្គការទន្លេអន្តរជាតិ

# ធនាគារពិភពលោកនិងទំនប់វារីអគ្គិសនី

## ផ្នែកទី២៖ ការបង្ហាញរឿងមិនពិតអំពីទំនប់វារីអគ្គិសនីណាំធឿន២

ដោយសន្មតថា សមិទ្ធផលនៃទំនប់វារីអគ្គិសនីរបស់ខ្លួនពោរពេញទៅដោយបញ្ហា ដូច្នេះធនាគារពិភពលោកបានសន្យាថា ទំនប់វារីអគ្គិសនីណាំធឿន២ នៅក្នុងប្រទេសឡាវ ជាគំរូថ្មីមួយសម្រាប់គម្រោងទំនប់វារីអគ្គិសនីប្រកបដោយចីរភាពនៅពេលដែលធនាគារនេះបានអនុម័តគម្រោងនៅឆ្នាំ២០០៥។ ចាប់ពីពេលនោះមក ធនាគារពិភពលោកបានលើកឡើងនូវជោគជ័យនៃគម្រោងជាការអះអាងដើម្បីបង្ហាញអំពីភាពត្រឹមត្រូវសម្រាប់ការបង្កើនការផ្តល់ប្រាក់កម្ចីសម្រាប់គម្រោងទំនប់វារីអគ្គិសនីធំៗទូទាំងពិភពលោក។ ដប់ឆ្នាំក្រោយមក តើការអះអាងអំពីទំនប់ណាំធឿន២ថា ជារឿងទទួលបានជោគជ័យនោះ នៅតែមានទឹកទេ?

ស្រ្តីម្នាក់ដែលរស់នៅតាមមាត់ទន្លេ Xe Bang Fai ដែលជាទន្លេមួយនៅក្នុងប្រទេសឡាវ ហើយដែលទន្លេនេះ ជាសរសៃឈាមរបស់ប្រជាពលរដ្ឋរាប់រយពាន់នាក់នោះ បាននិយាយថា "យើងជាប្រជាពលរដ្ឋក្រីក្រ។ យើងធ្លាប់ពឹងផ្អែកលើទន្លេនេះ ដើម្បីរកត្រីសាច់ធ្វើជាម្ហូបអាហារ និងរកប្រាក់ចំណូល។ ឥឡូវនេះ គ្មានអ្វីទេ"។ អ្វីដែលកាលពីមុនជាប្រភពជលផលយ៉ាងសម្បូរបែបនោះ គេឃើញថា ធ្លាក់ចុះយ៉ាងខ្លាំង ដោយសារតែ លទ្ធផលនៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីនៅខ្សែទឹកខាងលើ។

នៅឆ្នាំ២០០៥ ធនាគារពិភពលោកបានប្រកាស គាំទ្រទំនប់ណាំធឿន២ (ណាធ២) នៅភាគកណ្តាលប្រទេសឡាវ ដែលជាការត្រួសត្រាយផ្លូវសម្រាប់ការផ្តល់ហិរញ្ញវត្ថុបន្ថែមទៀតពីស្ថាប័នធនាគារអភិវឌ្ឍន៍ និងធនាគារហិរញ្ញប្បទានឯកជននានា។ ទំនប់វារីអគ្គិសនីណាំធឿន២ដែលមានកម្លាំង១០៧០មេហ្គាវ៉ាត់ ត្រូវបានគេសរសើរថា ជាអ្នករកប្រាក់បរទេស សម្រាប់ប្រទេសឡាវដែលជាប្រទេសក្រីក្រ។ វាក៏ជាការបោះជំហានយ៉ាងធំរបស់ធនាគារពិភពលោកជាលើកដំបូងចូលទៅក្នុងសេវាផ្តល់ហិរញ្ញវត្ថុសម្រាប់ទំនប់វារីអគ្គិសនីធំៗក្នុងរយៈពេលមួយទសវត្សរ៍។ ធនាគារនេះបានដកប្រាក់ជាច្រើនពីវិស័យនេះ ក្រោយពីមានភាពចម្រូងចម្រាសជាបន្តបន្ទាប់ជុំវិញផលប៉ះពាល់ដែលកើតឡើងដោយសារទំនប់វារីអគ្គិសនីដែលខ្លួនបានផ្តល់ប្រាក់កម្ចី។

ក្រោយពីដំណើរការរបស់គណៈកម្មាធិពិភពលោកស្តីពីទំនប់វារីអគ្គិសនី (WCD)[1] ដែលបានចងក្រងឯកសារអំពីផលប៉ះពាល់បរិស្ថាននិងសហគមន៍ដោ



ប្រជាជនជាច្រើនគ្រួសារដែលរស់នៅតាមខ្សែទឹកខាងក្រោមទំនប់ណាំធឿន២ រាយការណ៍ អំពីការប្រឈមកង្វះខាតស្បៀងអាហារដោយសារតែពួកគាត់បាត់បង់លទ្ធភាពធ្វើចម្ការដំណាំនៅតាមមាត់ទន្លេ និងកម្រិតទឹកឡើងចុះ ដែលបានបំផ្លាញផលដំណាំរបស់ពួកគាត់នៅតាមបណ្តោយទន្លេនេះ។ ខែវិច្ឆិកា ឆ្នាំ២០១៤, រូបថត៖ អង្គការទន្លេអន្តរជាតិ។

យសារសមិទ្ធផលពោរពេញទៅដោយបញ្ហានៃទំនប់វារីអគ្គិសនីនោះមក ធនាគារពិភពលោកបានសន្យាថា ទំនប់វារីអគ្គិសនីណាំធឿន២ នឹងបង្កើតវិធីសាស្ត្រថ្មីចំពោះគម្រោងទំនប់វារីអគ្គិសនីធំៗ ដោយបានហៅគម្រោងនេះថាជា "ករណីគំរូ" មួយ ដែលមាន "សក្តានុពល ត្រូវយកជាគំរូយ៉ាងទូលំទូលាយ។ ជាលទ្ធផល ធនាគារនេះបានចំណាយពេល ប្រាក់ និងធនធានមនុស្សយ៉ាងច្រើនទៅលើការគ្រប់គ្រងបញ្ហាលំបាកៗនៃគម្រោងអភិវឌ្ឍន៍ដ៏ស្មុគស្មាញ ដូចគម្រោងទំនប់វារីអគ្គិសនីណាំធឿន២បានប្រឈម។

ចាប់តាំងពីពេលដែលទំនប់នេះបានចាប់ផ្តើមផលិតអគ្គិសនីនៅក្នុងឆ្នាំ២០១០នោះមក ធនាគារពិភពលោកបានបង្ហាញករណីគម្រោងថាជាជោគជ័យមួយ ថែមទាំងចាត់ឲ្យមានការរៀបចំសៀវភៅមួយអំពីទំនប់នេះដោយដាក់ចំណងជើងសៀវភៅនេះថា ***ធ្វើឲ្យទំនប់វារីអគ្គិសនីកាន់តែប្រសើរ។*** ការអះអាងសំខាន់ៗដែលធនាគារពិភពលោកបានបន្តលើកឡើងអំពីគម្រោងទំនប់ណាំធឿន២ គឺ គម្រោងនេះ បានកាត់បន្ថយភាពក្រីក្រ, ការវិនិយោគក្នុងសម័យទំនើបធ្វើឲ្យសហគមន៍ដែលតាំងទីលំនៅថ្មីមានជីវភាពល្អប្រសើរជាងមុន, ហើយផលប៉ះពាល់លើសហគមន៍នៅខ្សែទឹកខាងក្រោមត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ជាអកុសល ដូចបានចង្អុលបង្ហាញដោយក្រុមជំនាញឯករាជ្យផ្ទាល់របស់ធនាគារថា ការអះអាងទាំងនេះ មិនមែនជាការឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងស្ថានភាពជាក់ស្តែងទេ (ដែលការបង្ហាញនោះកាន់តែសំខាន់ឡើងៗចំពោះដំណើរការអនុវត្តគម្រោងតាំងពីដើមរហូតដល់ចប់)។

ដោយសន្មតថា ធនាគារបន្តពឹងផ្អែកលើជោគជ័យដូចការអះអាងអំពីគម្រោងទំនប់ណាំធឿន២ ដើម្បីបង្ហាញភាពត្រឹមត្រូវក្នុងការបង្កើនការវិនិយោគលើទំនប់វារីអគ្គិសនីរបស់ខ្លួនពីប្រទេសនីហ្សេរីយ៉ា ទៅប្រទេសនេប៉ាល់ ដូច្នេះវាដល់ពេលដែលត្រូវមើលឲ្យកាន់តែច្បាស់លើការអះអាងដែលធនាគារពិភពលោកបានលើកឡើង។

## រឿងមិនពិតទី១៖ ការកាត់បន្ថយភាពក្រីក្រ

*"ណាធ២ នឹងផ្តល់ប្រាក់ចំណូលប្រចាំឆ្នាំប្រហែល២ប៊ីលានដុល្លារជាប្រាក់ចំណូលរបស់រដ្ឋាភិបាល ... ដោយរដ្ឋាភិបាលប្រើប្រាក់ចំណូលទាំងនោះដើម្បីកាត់បន្ថយភាពក្រីក្រ"* - ខិតប័ណ្ណវារីអគ្គិសនី ធនាគារពិភពលោក ឆ្នាំ២០១៤

ហេតុផលរបស់ធនាគារពិភពលោកសម្រាប់ការគាំទ្រគម្រោងណាមធឿន២គឺការគ្រប់គ្រងនិងប្រើប្រាស់ទន្លេរបស់ខ្លួនគឺជាជម្រើសមួយក្នុងចំណោមជម្រើសនានាសម្រាប់ប្រទេសឡាវដើម្បីបង្កើតប្រាក់ចំណូលដែលរដ្ឋាភិបាលខ្វះខាតយ៉ាងច្រើន។ ជាការពិតណាស់ អគ្គិសនីនៃគម្រោងនេះ៩៥% ត្រូវនាំចេញទៅប្រទេសថៃ។ ដូច្នេះហើយ ហេតុផលអភិវឌ្ឍន៍របស់គម្រោង - និងជោគជ័យចុងក្រោយរបស់ខ្លួន - តែងតែពឹងផ្អែកមួយផ្នែកធំលើការបង្កើតប្រាក់ចំណូលដើម្បីផ្តល់មូលនិធិដល់កម្មវិធីអភិវឌ្ឍន៍ដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេស។

ដោយយសារអំពើពុករលួយរាំរ៉ៃ និងបញ្ហាប្រឈមនៃអភិបាលកិច្ចនៅក្នុងប្រទេសឡាវ ដែលជាលក្ខខណ្ឌនៃការគាំទ្ររបស់ខ្លួននោះ ធនាគារពិភពលោក បានបញ្ចូលវិធានការគួរឲ្យចម្លែកតាមរយៈការបង្កើតកម្មវិធីគ្រប់គ្រងចំណូលចំណាយដើម្បីតាមដានប្រាក់ចំណូលពីគម្រោងនិងធានាឱ្យបាននូវការចំណាយលើកម្មវិធីអភិវឌ្ឍន៍។

ប៉ុន្តែ ទោះបីជាមានសេចក្តីរាយការណ៍ថា ទំនប់ណាំធឿន២ បាន "បង្កើតប្រាក់ចំណូលច្រើនជាងការរំពឹងទុក" ដោយផលិតបានលើសគោលដៅនៃការនាំអគ្គិសនីចេញក៏ដោយ ក៏ធនាគារពិភពលោកបានសារភាពថា ប្រាក់ចំណូលតិចជាងពាក់កណ្តាលត្រូវបានគណនាយ៉ាងល្អិតល្អន់ ជាចំណែកដែលពិតជាធ្លាក់ចុះ។

មិនថាតែរដ្ឋាភិបាលឡាវទេដែលមិនបានប្រកាសរបាយការណ៍ហិរញ្ញវត្ថុ ឬសវនកម្មហិរញ្ញវត្ថុរបស់ខ្លួន ក្នុងរយៈពេលប្រាំឆ្នាំគិតចាប់តាំងពីទំនប់ណាំធឿន២ ត្រូវចាត់ឲ្យដំណើរការ សូម្បីតែក្រុមហ៊ុនក៏មិនបានបង្ហាញតួលេខប្រាក់ចំណូលប្រចាំឆ្នាំដែរ។ ដោយមានការរឹតត្បិតលើសេរីភាពពលរដ្ឋនិងនយោបាយប្រជាពលរដ្ឋឡាវគ្មានវិធីទាមទារឲ្យមានតម្លាភាពនិងគណនេយ្យភាពនោះឡើយ។ មិនទាំងបានធានានូវការកាត់បន្ថយភាពក្រីក្រសម្រាប់ប្រទេសឡាវនោះទេ គម្រោងនេះបែរជាធ្វើឲ្យមានការលំបាកយ៉ាងធ្ងន់ធ្ងរដល់អ្នកដែលចំណាយលើគម្រោងនេះទៅវិញ។

## រឿងមិនពិតទី២៖ ជីវភាពរបស់សហគមន៍តាំងទីលំនៅថ្មី ល្អប្រសើរ

*"បច្ចុប្បន្ន គ្រួសារអ្នកតាំងទីលំនៅថ្មីភាគច្រើនមានជីវភាពគ្រាន់បើជាងមុនពេលមានគម្រោង"* - របាយការណ៍ស្តីពីការរីកចម្រើន ឆ្នាំ២០១៣ ដោយធនាគារពិភពលោក

ទីផ្សារចម្បងរបស់ធនាគារពិភពលោកពាក់ព័ន្ធនឹងទំនប់ណាំធឿន២ គឺដំណើរការដែលត្រូវអនុវត្តដើម្បីផ្លាស់ប្តូរទីលំនៅ និងតាំងទីលំនៅថ្មីសម្រាប់ប្រជាជនប្រមាណជិត៦៣០០នាក់ ដែលត្រូវបង្ខំឱ្យរុះរើលំនៅដ្ឋានដើម្បីបើកផ្លូវសម្រាប់អាងទំនប់វារីអគ្គិសនីនោះ។ ធនាគារផ្តល់អាទិភាពយ៉ាងត្រឹមត្រូវលើការតាំងទីលំនៅថ្មីតាមរបាយការណ៍របស់គណៈកម្មាធិពិភពលោកស្តីពីទំនប់វារីអគ្គិសនី និងការស្រាវជ្រាវផ្ទាល់របស់ធនាគារ ដែលបានចងក្រងឯកសារស្តីពីភាពក្រីក្ររយៈពេលវែងដែលបណ្តាសហគមន៍ប្រឈមមុខនឹងការផ្លាស់ប្តូរកន្លែងរស់នៅដោយសារទំនប់វារីអគ្គិសនី។

ដើម្បីបញ្ចៀសលទ្ធផលនេះ ធនាគារនិងដៃគូរបស់ខ្លួនបានយល់ព្រមបណ្តាក់ទុនជិត៨០លានដុល្លារ និងចំណាយពេល ប្រើប្រាស់បុគ្គលិកគ្រប់គ្រាន់ ដើម្បីបង្កើតនិងអនុវត្តផែនការតាំងលំនៅថ្មី ដែលរួមមានការវិនិយោគយ៉ាងសំខាន់ទៅលើតំបន់តាំងទីលំនៅថ្មីនៅខ្ពង់រាបណាកៃ (Nakai Plateau)។ ជាការពិតណាស់ថាមានការសង្ស័យតិចតួច ព្រោះថាឥឡូវនេះ គ្រួសារប្រជាពលរដ្ឋដែលតាំងទីលំនៅថ្មី មានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានល្អប្រសើរជាងមុន ដោយសារគម្រោងនេះមានដូចជា លំនៅដ្ឋាន អគ្គិសនី ផ្លូវថ្នល់ សាលារៀន និងមណ្ឌលសុខភាព។

ទោះជាយ៉ាងនេះក្តី រយៈពេលជាច្រើនឆ្នាំចាប់តាំងពីពេលដែលពួកគាត់ត្រូវគេឲ្យផ្លាស់ប្តូរទីតាំងនោះមក បណ្តាសហគមន៍ដែលបានតាំងលំនៅថ្មីទាំងនោះ នៅតែមានការលំបាកដោយការបាត់បង់របរចិញ្ចឹមជីវិតតាមបែបប្រពៃណីរបស់ពួកគាត់ ដោយបាត់បង់លទ្ធភាពប្រើប្រាស់ដីស្រែនិងចម្ការ ព្រៃ និងវាលស្មៅ។ ដីឡូត៍ដែលមានទំហំតូចនិងគុណភាពអន់នៅក្នុងតំបន់តាំងទីលំនៅថ្មី នៅតែបន្តបង្កឱ្យមានបញ្ហាសម្រាប់អ្នកភូមិដែលមិនអាចដាំដំណាំគ្រប់គ្រាន់ឬចិញ្ចឹមសត្វបាន។ ដោយទំហំដីនៅតំបន់ខ្ពង់រាបណាកៃ មានកំណត់ ប្រជាជនជាច្រើនគ្រួសារក្នុងចំណោមគ្រួសារទាំងនោះ បានស្វែងរកវិធីទិញដីនៅកន្លែងផ្សេង ឬរកប្រាក់ចំណូលពីដីគ្រួសារកសិករ នៅទីតាំងឆ្ងាយៗ។

ទន្ទឹមគ្នានេះដែរ ការចិញ្ចឹមត្រីនៅក្នុងស្រះ ដែលជាមធ្យោបាយជំនួសការនេសាទត្រីទន្លេ ជារបរចិញ្ចឹមជិវិតសម្រាប់រយៈពេលវែងនោះ បានធ្លាក់ចុះគួរឲ្យកត់សម្គាល់ ហើយការរឹតត្បិតលើសិទ្ធិប្រើប្រាស់អាងទឹក រួមទាំងការផ្តល់អាជ្ញាប័ណ្ណផង ធ្វើឲ្យកំណើនប្រាក់ចំណូលតាមការប៉ាន់ស្មានពីការនេសាទត្រីពីអាងសម្រាប់អ្នកតាំងលំនៅថ្មី ជាក់ស្តែងមិនបានកើតចេញជាផ្លែផ្កាទេ។

ទោះបីជា ការវិនិយោគដំបូងទៅលើហេដ្ឋារចនាសម្ព័ន្ធ បានដំណើរការគួរឲ្យចាប់អារម្មណ៍ក៏ដោយ ក៏និរន្តរភាពនៃការវិនិយោគនោះ កំពុងស្ថិតក្នុងស្ថានភាព

## រឿងមិនពិតផ្សេងៗទៀត

- **រឿងមិនពិត៖** *គម្រោងទំនប់វារីអគ្គិសនីណាំធឿន២ផលិតថាមពលបៃតង។* **ជាក់ស្ដែង៖** ការសិក្សាមួយនៅឆ្នាំ២០១៥ ដែលធ្វើឡើងដោយអ្នកគាំទ្រគម្រោងបានបង្ហាញថា អាងស្ដុកទឹកនេះកំពុងបញ្ចេញឧស្ម័នមេតានក្នុងបរិមាណច្រើនជាងការប៉ាន់ប្រមាណ។ ឧស្ម័នមេតានជាឧស្ម័នផ្ទះកញ្ចក់ដែលមានកម្លាំងខ្លាំងជាងកាបូនឌីអុកស៊ីត២៥ដង ហើយតាមការសិក្សាវិទ្យាសាស្ត្របានបង្ហាញថា ការបញ្ចេញឧស្ម័នមេតានពីអាងស្ដុកទឹកទំនប់វារីអគ្គិសនីគឺជាប្រភពកំដៅផែនដី គួរឲ្យកត់សម្គាល់។
- **រឿងមិនពិត៖** *គម្រោងទំនប់វារីអគ្គិសនីណាំធឿន២ ជាគំរូនៃការពិគ្រោះយោបល់ជាសាធារណៈ។* **ជាក់ស្ដែង៖** ដោយពុំមានសេរីភាពនៃការបញ្ចេញមតិនៅក្នុងប្រទេសឡាវ និងដោយមានការរឹតបន្តឹងធ្ងន់ធ្ងរលើសង្គមស៊ីវិល ការពិគ្រោះយោបល់ជាផ្លែផ្កាមិនអាចកើតឡើងបានទេ។ បណ្ដាសហគមន៍នៅខ្សែទឹកខាងក្រោមមិនបានដឹងអំពីគម្រោងនេះ ឬផលប៉ះពាល់ដែលអាចកើតឡើងពីគម្រោងនេះទេ រហូតដល់ក្រោយពេលមានការសម្រេចចិត្តដើម្បីអភិវឌ្ឍគម្រោងនេះទើបពួកគាត់ដឹង។
- **រឿងមិនពិត៖** *គម្រោងទំនប់វារីអគ្គិសនីណាំធឿន២ជាជម្រើសល្អបំផុតដែលអាចមាន។* **ជាក់ស្ដែង៖** ពុំដែលមានអនុវត្តការសិក្សាវាយតម្លៃអំពីជម្រើសល្អប្រសើរសម្រាប់ផលិតកម្មថាមពល ឬការបង្កើតប្រាក់ចំណូលនៅក្នុងប្រទេសឡាវទេ។ ដូចគ្នានេះដែរ ការសម្រេចចិត្តក្នុងការនាំចេញថាមពល គឺផ្អែកលើការប៉ាន់ប្រមាណបំប៉ោងអំពីតម្រូវការក្នុងប្រទេសថៃ។ នៅពេលដែលវារីអគ្គិសនីណាំធឿន២បានចាប់ផ្ដើមដំណើរការផលិតអគ្គិសនីសម្រាប់លក់ទៅប្រទេសថៃនៅ២០១០ ប្រទេសថៃមានអគ្គិសនីលើសតម្រូវការទៅហើយ។

គ្រោះថ្នាក់ ដោយសារគ្មានមូលនិធិសម្រាប់ការថែរក្សានិងជួសជុល និងមិនសមស្របសម្រាប់ប្រជាជនដែលកើនឡើង។ កាន់តែសំខាន់ជាងនោះទៅទៀត ផែនការរបស់គម្រោងដែលធានាថា ជីវភាពរបស់ប្រជាជនត្រូវបានស្ដារឡើងវិញ និងទ្រទ្រង់ក្នុងរយៈពេលយូរនោះ មិនបានបង្ហាញឲ្យឃើញជាផ្លែផ្កាទេ។

## រឿងមិនពិតទី៣៖ ផលប៉ះពាល់នៅខ្សែទឹកខាងក្រោមត្រូវបានគ្រប់គ្រង

*“កម្រិតនៃផលប៉ះពាល់នៅខ្សែទឹកខាងក្រោមមានកម្រិតស្មើ ឬកាន់តែតិចជាងអ្វីដែលបានគ្រោងទុក”* - វីឌីអូផ្សាយពាណិជ្ជកម្ម របស់ធនាគារពិភពលោក ឆ្នាំ២០១២

ទំនប់វារីអគ្គិសនីណាំធឿន២ គឺជាប្រព័ន្ធវារីអគ្គិសនីឆ្លងអាង ដែលអគ្គិសនីត្រូវបានបង្កើតឡើងអំឡុងពេលផ្ទេរទឹកពីទន្លេធឿន ទៅទន្លេ Xe Bang Fai ដែលជាទន្លេតូចជាង។ នេះធ្វើឲ្យមានការផ្លាស់ប្ដូរយ៉ាងខ្លាំងផ្នែកវារីសាស្ត្រនៃទន្លេ Xe Bang Fai រួមទាំងធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក និងរំហូរទឹកខ្លាំងច្រើនពេញមួយឆ្នាំ ដែលអាចនឹងត្រូវគេនិយាយពន្លើសសម្រាប់ផែនការពង្រីកគម្រោងនៅពេលអនាគត។

ក្រោយពីការពិនិត្យឡើងវិញអំពីហានិភ័យដែលអាចនឹងកើតឡើងចំពោះទន្លេ Xe Bang Fai ធនាគារពិភពលោក ត្រូវទទួលរងនូវសម្ពាធ ក្នុងការពិនិត្យផលប៉ះពាល់លើប្រជាពលរដ្ឋចំនួន១២០.០០០នាក់ ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារការប្រែប្រួលទឹកទន្លេ Xe Bang Fai និងរៀបចំផែនការផ្ដល់សំណងដល់ពួកគាត់សម្រាប់ការបាត់បង់ទ្រព្យសម្បត្តិ និងជួយដល់ប្រជានេសាទ និងកសិករផ្សាំខ្លួនទៅនឹងការប្រើប្រាស់ទន្លេដែលខុសគ្នាទាំងស្រុង។ ធនាគារពិភពលោកបានរៀបចំបង្កើតកម្មវិធីខ្សែទឹកខាងក្រោម ដើម្បីផ្ដល់មូលនិធិសម្រាប់គោលបំណងនេះ។ ទោះជាយ៉ាងនេះក្ដី ការដាក់ឲ្យដំណើរការមិនបានដល់៣ឆ្នាំផង កម្មវិធីនេះក៏ត្រូវប្រគល់ទៅឲ្យរដ្ឋាភិបាលឡាវ ហើយបន្ទាប់មកក៏ត្រូវបញ្ឈប់ដោយសារអស់មូលនិធិមុនកំណត់។

ទោះបីជាមាន ការអះអាងដោយធនាគារថា ផលប៉ះពាល់នៅខ្សែទឹកខាងក្រោមត្រូវបានកាត់បន្ថយហើយក្ដី ក៏ក្រុមអ្នកស្រាវជ្រាវដែលបានចុះទៅដល់បណ្ដាភូមិនៅខ្សែទឹកខាងក្រោម នៅឆ្នាំ២០០១ និងចុះទៅជាថ្មីម្ដងទៀតនៅឆ្នាំ២០១៥ បានរកឃើញថា “មានការផ្លាស់ប្ដូរយ៉ាងខ្លាំងនូវលទ្ធភាពរបស់អ្នកភូមិក្នុងការទ្រទ្រង់ដល់សន្តិសុខស្បៀង និងប្រាក់ចំណូលពីជលផលទន្លេ Xe Bang Fai”។[2] ការប្រែប្រួលប្រព័ន្ធជីវសាស្ត្រទន្លេ បានធ្វើឲ្យអ្នកភូមិប្រឈមការថយចុះយ៉ាងខ្លាំងនូវបរិមាណត្រីដែលរកបាន ដែលពីមុនធ្លាប់តែជាផ្នែកយ៉ាងសំខាន់នៃរបបចិញ្ចឹមជីវិតរបស់ពួកគាត់។ ផលប៉ះពាល់នេះបានធ្លាក់យ៉ាងធ្ងន់ទៅលើស្ត្រី ដោយសារតែពួកគាត់ពឹងផ្អែកលើទន្លេក្នុងការប្រាក់ចំណូល។

ដូចគ្នានេះដែរ ការធ្វើស្រែរដូវវស្សាបានថយចុះ ដោយសារតែទឹកជំនន់ខ្លាំងពីការបង្ហូរទឹកចេញពីទំនប់វារីអគ្គិសនី ហើយផែនការធ្វើស្រែរដូវប្រាំងត្រូវបរាជ័យ ដោយសារចំណាយច្រើនលើអគ្គិសនីសម្រាប់បូមទឹកទន្លេបញ្ចូលស្រែ។ ប្រជាជនដែលរស់នៅតាមបណ្ដោយទន្លេ Xe Bang Fai រហូតដល់ចំណុចប្រសព្វទន្លេមេគង្គ ចម្ងាយ១០០គីឡូម៉ែត្រនោះ មានស្ថានភាពកាន់តែអន់ទៅទៀត។

## គំរូបរាជ័យត្រូវយកមកអនុវត្តតាម

ធនាគារពិភពលោកបានបន្តឃោសនា ជាបន្តបន្ទាប់ អំពីរឿងនានាពាក់ព័ន្ធនឹងគម្រោងទំនប់ណាំធឿន២ ដោយផ្សព្វផ្សាយថា វាជាគំរូសម្រាប់គម្រោងទំនប់វារីអគ្គិសនីធំៗដើម្បីអនុវត្តតាម។ ដប់ឆ្នាំក្រោយមកចាប់តាំងពីការអនុម័ត និងប្រាំឆ្នាំចាប់តាំងពីទំនប់ណាំធឿន២ ដំណើរការផលិតអគ្គិសនី វាជាការសំខាន់ណាស់ដែលត្រូវគិតពិចារណា និងរៀនពីមេរៀនទាំងនេះ។ គួរឲ្យបារម្ភ ដែលធនាគារហាក់ដូចជាធ្វើកំហុសដែលខ្លួនបានធ្វើដដែលៗ ពាក់ព័ន្ធទំនប់ណាំធឿន២ ក្នុងការបង្កើតទំនប់វារីអគ្គិសនីថ្មីៗ៖

- **ការកាត់បន្ថយភាពក្រីក្រពីទំនប់វារីអគ្គិសនីអ៊ីងហ្គា៣៖** ដូចគ្នានឹងទំនប់វារីអគ្គិសនីណាំធឿន២ដែរ ហេតុផលសម្រាប់អភិវឌ្ឍន៍ទំនប់វារីអគ្គិសនីអ៊ីងហ្គា៣ ដែលមានតម្លៃ ១៤ពាន់លានដុល្លារ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) ត្រូវបានប៉ាន់ស្មានលើការបង្កើតប្រាក់ចំណូលសម្រាប់រដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ។ ប៉ុន្តែ លទ្ធភាពនៃការធានាតម្លាភាពគណនេយ្យភាព និងការអនុវត្តបន្តដំណើរការទំនប់វារីអគ្គិសនីអ៊ីងហ្គា៣ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ មិនច្បាស់លាស់ទេ នេះប្រហែលជាងាយប្រឈមអំពើពុករលួយនិងការគ្រប់គ្រងហិរញ្ញវត្ថុមិនល្អជាងនៅប្រទេសឡាវ។ លទ្ធផលគម្រោង មិនគួរឲ្យសប្បាយចិត្តសោះ។ ទោះបីជាមានស្នាដៃសំខាន់ៗក្នុងការធានានូវតម្លាភាពក្នុងវិស័យរ៉ែ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ តាមរយៈគម្រោងផ្ដួចផ្ដើមតម្លាភាពឧស្សាហកម្មនិស្សារណកម្មក៏ដោយ ក៏មានភស្តុតាងតិចតួចបញ្ជាក់ថា មូលនិធិទាំងនេះបានទៅដល់ដៃអ្នកដែលត្រូវការវា។
- **ការតាំងទីលំនៅថ្មីនៅទំនប់កាន់ដាតជី នៅនីហ្សេ៖** ធនាគារពិភពលោកបានចំណាយការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើដំណាក់កាលដំបូងនៃដំណើរការតាំងលំនៅថ្មី (៥៤១០នាក់) នៅឯទំនប់វារីអគ្គិសនីកាន់ដាតជី (Kandadji) នៅនីហ្សេដែលគួរឲ្យសប្បាយចិត្តដោយមានបញ្ចូលបទប្បញ្ញត្តិសម្រាប់ការចែកផលចំណេញពីប្រាក់ចំណូលប្រចាំឆ្នាំដើម្បីគាំទ្រដល់សហគមន៍ដែលបានទៅតាំងទីលំនៅថ្មី។ ផែនការស្ដារជីវភាពឡើងវិញ នៅតែពឹងផ្អែកលើវិស័យកសិកម្មប្រព័ន្ធស្រោចស្រព នៅខ្សែទឹកខាងក្រោមនៃទំនប់

> *“គម្រោងទំនប់អគ្គិសនីណាំធឿន២ អះអាងបញ្ជាក់លើការសង្ស័យជាយូរមកហើយរបស់ខ្ញុំដែលថាការងារសាងសង់ទំនប់វារីអគ្គិសនីយ៉ាងធំបែបនេះ មានភាពស្មុគ្រស្មាញណាស់ ហើយក៏បង្កការខូចខាតយ៉ាងខ្លាំងណាស់ដែរ លើធនធានធម្មជាតិដែលមានតម្លៃមិនអាចកាត់ថ្លៃបាន។”*
>
> លោក Thayer Scudder សមាជិកក្រុមអ្នកជំនាញបរិស្ថានអន្តរជាតិលើកឡើងថា



គ្មានការយកចេញនូវជីវម៉ាស់នៅការដ្ឋានអាងទឹកនាំឲ្យមានកម្រិតឧស្ម័នមេតានច្រើនហួសការស្មាន និងចំហាយបំភាយឧស្ម័នផ្ទះកញ្ចក់ផ្សេងទៀត។ ខែវិច្ឆិកា ឆ្នាំ២០១៤, រូបថត៖ អង្គការទន្លេអន្តរជាតិ។

ដែលមានលទ្ធផលមិនសូវល្អទេនៅអាហ្វ្រិក ដើម្បីជំនួសវិធីសាស្ត្រដាំដុះបែបប្រពៃណី ធ្វើស្រែប្រដេញទឹក និងការនេសាទ។ សូម្បីមានប្រាក់ចំណូលកើនសម្រាប់គម្រោងសហគមន៍ដែលបានមកពីទំនប់វារីអគ្គិសនីនេះក៏ដោយ ក៏ប្រជាជនដែលតាំងទីលំនៅថ្មី អាចមានការពិបាកក្នុងការផ្គត់ផ្គង់ខ្លួនឯងដែរ។ លទ្ធភាពនៃការប្រឈមការលំបាកក្នុងការធានាសន្តិសុខស្បៀងអាហារនៅពេលដែលដំណាក់កាលទីពីរ (៣២៥០០នាក់) ត្រូវបានបញ្ចប់ រឹតតែគួរឲ្យបារម្ភ។

- **ផលប៉ះពាល់នៅខ្សែទឹកខាងក្រោមពីទំនប់វារីអគ្គិសនីហ្វូមី នៅហ្គីណេ៖** បច្ចុប្បន្ននេះ ធនាគារពិភពលោកបានគាំទ្រការងាររៀបចំមុន នៅឯក្បាលទឹកនៃទន្លេនីហ្សេសម្រាប់ទំនប់វារីអគ្គិសនីហ្វូមី នៅប្រទេសហ្គីណេ ដូចទំនប់ណាំធឿន២ដែរ បណ្ដាលឲ្យមានការរំខានយ៉ាងខ្លាំងដល់សហគមន៍ដែលរស់នៅខ្សែទឹកខាងក្រោម។ ជាពិសេស ជនងាយរងគ្រោះគឺ ប្រជាជនជិត២លាននាក់នៅខ្សែទឹកខាងក្រោមនៅម៉ាលី - ដូចជា គ្រូគង្វាល កសិករ និងអ្នកនេសាទ - ដែលពឹងផ្អែកលើទឹកជំនន់ប្រចាំឆ្នាំនៃដីសណ្ដនីហ្សេខាងក្នុង ដែលជាតំបន់ដីសើមមួយក្នុងចំណោមតំបន់ដីសើមធំៗបំផុតនៅអាហ្វ្រិក សម្រាប់ជាដីវាលស្មៅ និងជាដីមានជីជាតិតំបន់លិចទឹក និងដើម្បីទ្រទ្រង់និងជាអាងរក្សាត្រី។ ហ្វូមី កំពុងត្រូវបានស្នើជាគម្រោង "ទំនប់មានច្រើនគោលបំណង" ដែលនឹងជួយសម្រួលដល់ការពង្រីកប្រព័ន្ធធារាសាស្ត្រយ៉ាងធំហួតដល់ដីដែលត្រូវបានត្រៀមទុកសម្រាប់វិនិយោគិនបរទេសនៅក្នុងតំបន់ប្រព័ន្ធធារាសាស្ត្ររបស់ប្រទេសម៉ាលី។ ទំនុកចិត្តរបស់ធនាគារពិភពលោកដែលថា កិច្ចសន្យាត្រូវគ្រប់គ្រងបាន អាចធ្វើឲ្យមានភាពស្ងប់ចិត្តតិចតួចចំពោះក្រុមប្រជាពលរដ្ឋទន់ខ្សោយ នៅដីសណ្ដនីហ្សេខាងក្នុង។

ទំនប់ណាំធឿន២ ត្រូវគេសន្មតថាខុសគេ ដោយធនាគារពិភពលោកធ្វើបានល្អប្រសើរជាងក្នុងការផ្ដល់នូវគំរូវិជ្ជមានសម្រាប់គ្រប់គ្រងហានិភ័យ ដែលទំនប់វារិអគ្គិសនីធំៗបង្កឡើងដល់បរិស្ថាន និងបណ្ដាសហគមន៍ និងសម្រាប់ផ្ដល់ការអភិវឌ្ឍពិតប្រាកដ។ ជាថ្មីម្ដងទៀត ដោយសារធនាគារពិភពលោកបានវិនិយោគនៅក្នុងគម្រោងទំនប់វារីអគ្គិសនីធំៗដោយមានការសន្យានូវគម្រោង "វារីអគ្គិសនីប្រកបដោយនិរន្តរភាព" ដូច្នេះជាអកុសល ធនាគារនេះនៅតែខកខានមិនបានរៀនពីកំហុសអតីតកាលរបស់ខ្លួនឡើយ។

## កំណត់សម្គាល់

1. គណៈកម្មការពិភពលោកស្ដីពីទំនប់វារីអគ្គិសនីគឺជាដំណើរការពហុភាគីពាក់ព័ន្ធដែលបានស្រាវជ្រាវអំពីផលប៉ះពាល់សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថានដែលបណ្ដាលមកពីទំនប់វារីអគ្គិសនីធំៗ។ គណៈកម្មការនេះ បានបញ្ចប់ការស្រាវជ្រាវ នៅឆ្នាំ២០០០ និងបានបង្កើតគោលការណ៍ណែនាំលម្អិតសម្រាប់ការអភិវឌ្ឍទំនប់វារីអគ្គិសនីប្រកបដោយការទទួលខុសត្រូវ។
2. *ប្រជាជននិងទន្លេរបស់ពួកគាត់, ធនាគារពិភពលោកនិងទំនប់វារីអគ្គិសនីរបស់ខ្លួន៖ ចុះពិនិត្យទន្លេ* Xe Bang Fai *ជាថ្មី នៅប្រទេសឡាវ* ដោយ Ian G. Baird, Bruce P. Shoemaker និង Kanokwan Manorom, អភិវឌ្ឍន៍និងការផ្លាស់ប្ដូរ, ខែកញ្ញា ឆ្នាំ២០១៥។

## JOIN US!

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ទំព័រស្ដីពីការសាងសង់ទំនប់វារីអគ្គិសនីតាមទន្លេមេគង្គតាមអាសយដ្ឋាន៖**
internationalrivers.org